ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤

# ញត្តិទាមទារ

# ការដោះលែងបេក្ខជនជាប់ឆ្នោតតំណាងរាស្ត្រ

# សំដែងមតិនៅទីលានប្រជាធិបតេយ្យ

ក្រុមអង្គការសង្គមស៊ីវិល មានការខកចិត្ត និងសោកស្តាយយ៉ាងខ្លាំងចំពោះព្រឹត្តិការណ៍ប្រទូស្តរ៉ាយគ្នាកាលពីព្រឹកថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១៤ វេលាម៉ោង៩ព្រឹករវាងប្រជាពលរដ្ឋម្ចាស់ឆ្នោត បេក្ខជនតំណាងរាស្ត្រជាប់ឆ្នោត ដែលចង់បញ្ចេញមតិធ្វើកូដកម្មដោយសន្តិភាពជាមួយនឹងកងសន្តិសុខខណ្ឌដូនពេញនៅចំណុចស្ពាននាគ នឹងទីលានប្រជាធិបតេយ្យ នៃរាជធានីភ្នំពេញដែលជាកន្លែងបញ្ចេញមតិរបស់ម្ចាស់ឆ្នោត។ ការប្រទូស្តរ៉ាយគ្នានេះបង្កឲ្យមានរបួសចំនួន៣១នាក់ ដែលក្នុងនោះខាងកងសន្តិសុខខណ្ឌមានចំនួន១៧នាក់ និងមានការឃាត់ខ្លួនមន្ត្រីគណបក្សសង្គ្រោះជាតិ១នាក់ និងបេក្ខជនតំណាងរាស្ត្រជាប់ឆ្នោត៥នាក់ ជាពិសេសបេក្ខជនស្ត្រីជាប់ឆ្នោតជាអ្នកតំណាងតំណាងរាស្ត្រ លោកស្រី មួរ សុខហួរ ផងដែរ។ ទង្វើនៃការចាប់ឃាត់ខ្លួនទាំងនេះ វាមិនស្របនឹងស្ថានភាពបច្ចុប្បន្ន ខណៈពេលដែលមិនទាន់មានការប្រកាសអាសន្នជាផ្លូវការដោយព្រះមហាក្សត្រ និងរដ្ឋាភិបាលកម្ពុជានៅឡើយទេ។ ទន្ទឹមនឹងនេះដែរ នាយករដ្ឋមន្ត្រីក៏បានមានប្រសាសន៍ថា ប្រទេសកម្ពុជា ជាស្ថាប័នរដ្ឋដែលនៅមានដំណើរការជាធម្មតា។ វិធានការ បង្ក្រាបមិនមែនជាដំណោះស្រាយក្នុងបរិបទ «កម្ពុជា» ទេ។ រដ្ឋាភិបាលមានកាតព្វកិច្ចការពារដល់ប្រជាពលរដ្ឋក្នុងការអនុវត្តសិទ្ធិរបស់ពួកគេ ក្នុងករណីនេះ ការបញ្ចេញមតិរបស់ក្រុមបក្សប្រឆាំង និងអ្នកដែលមានមតិ និងការព្រួយបារម្ភស្របផងដែរ។ ក្រុមអង្គការសង្គមស៊ីវិលបានឃើញ បានតាមដានសភាពការណ៍នេះយ៉ាងយកចិត្តទុកដាក់បំផុត និងយល់ថា លោកស្រី មួរ សុខហួរ មានគោលការណ៍នៃការទាមទារ និងតវ៉ាដោយអហឹង្សា។

ក្រុមអង្គការសង្គមស៊ីវិល ទាមទារឲ្យរដ្ឋាភិបាល និងអាជ្ញាធរពាក់ព័ន្ធទាំងឡាយ តុលាការមានសមត្ថកិច្ចធ្វើការដោះលែង និងដកការចោទប្រកាន់ដោយគ្មានលក្ខខណ្ឌចំពោះ លោកស្រី មួរ សុខហួរ និងបេក្ខជនតំណាងរាស្ត្រជាប់ឆ្នោតទាំងនោះជាបន្ទាន់។ បើដូចការបកស្រាយរបស់រដ្ឋាភិបាល និងរដ្ឋសភាថា រដ្ឋសភាអាណត្តិថ្មីត្រូវបានបង្កើត បច្ចុប្បន្នមានសុពលភាពនៃសមាជិកតំណារាស្ត្រ១២៣នាក់ នោះរដ្ឋាភិបាល អាជ្ញាធរ និងតុលាការត្រូវតែគោរព និងអនុវត្តតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមាត្រា៨០ «តំណាងរាស្ត្រមានអភ័យឯកសិទ្ធិសភា។ តំណាងរាស្ត្ររូបណាក៏ដោយមិនអាចត្រូវបានចោទប្រកាន់ ចាប់ខ្លួន ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិ ក្នុងការបំពេញមុខងាររបស់ខ្លួនឡើយ។...» និងច្បាប់វិសោធនកម្មនៃបទបញ្ជាផ្ទៃក្នុងនៃរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ប្រការ៤ថ្មី ចែងថា «តំណាងរាស្ត្រមានឋានៈ និងបុព្វសិទ្ធិស្មើនឹងឧត្តមមន្ត្រីផុតលេខនៃព្រះរាជាណាចក្រកម្ពុជា។...» និងការការពារសិទ្ធិធ្វើកូដកម្ម និងបាតុកម្ម មានចែងក្នុងមាត្រា៣៧ «សិទ្ធិធ្វើកូដកម្ម និងធ្វើបាតុកម្មដោយសន្តិវិធី ត្រូវយកមកអនុវត្តនៅក្នុងក្របខណ្ឌនៃច្បាប់» និងបានការពារសិទ្ធិសេរីភាពបញ្ចេញមតិ ដែលមានចែងក្នុងមាត្រា៤១ «ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ ។...» ។ បន្ថែមលើនេះទៀត យោងតាមកតិកាសញ្ញាអន្តរជាតិ ស្តីពី សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា១៩ កថាខណ្ឌ២ ចែងថា «ជនគ្រប់រូបមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ សិទ្ធិនេះ ត្រូវរាប់បញ្ចូលទាំងសេរីភាពស្រាវជ្រាវព័ត៌មានទទួល និងផ្សព្វផ្សាយព័ត៌មាន និងគំនិតសព្វបែបយ៉ាងដោយមិនគិតពីព្រំដែន ដោយផ្ទាល់មាត់ ឬបោះពុម្ព តាមទំរង់សិល្បៈក្តី ឬក៏ដោយមធ្យោបាយផ្សព្វផ្សាយដ៏ទៃទៀតក្តី តាមការជ្រើសរើសរបស់ខ្លួន»។

ក្រុមអង្គការសង្គមស៊ីវិលបន្តស្នើឲ្យអាជ្ញាធរ និងរាជរដ្ឋាភិបាល ៖

- សូមឲ្យមានការស៊ើបអង្កេតឲ្យបានហ្មតចត់ តម្លាភាព និងយុត្តិធម៌ ទៅលើជនដែលបានបង្ករហេតុ និងបានប្រព្រឹត្តិពិតប្រាកដក្នុងហេតុការណ៍ហិង្សាកាលពីថ្ងៃទី១៥ កក្កដា ២០១៤
- ត្រូវបើកទីលានប្រជាធិបតេយ្យវិញ ហើយត្រូវគោរព និងអនុវត្តតាមរដ្ឋធម្មនុញ្ញ និងច្បាប់បាតុកម្មដោយសន្តិវិធី ព្រោះថាបើមិនការដោះលែងនោះទេអាចនឹងបណ្ដាលឲ្យមានភាពវឹកវរ និងអាចបង្កឲ្យមានអស្ថេរភាពនៅក្នុងសង្គមកម្ពុជាដែលនិងប៉ះពាល់ដ៏ធ្ងន់ធ្ងរដល់សេដ្ឋកិច្ច និងជីវិតរស់នៅរបសប្រជាពលរដ្ឋ។

**អង្គការសង្គមស៊ីវិលគាំទ្រញត្តិនេះ៖**

| | | |
|---|---|---|
| -លោក គល់ បញ្ញា | នាយកប្រតិបត្តិCOMFREL | 012 49 20 17 |
| -លោកស្រី ធីតា យឹះ | ប្រធានCPWP និងនាយិកា SILAKA | 012 38 84 64 |
| -លោកស្រី រស់ សុភាព | អនុប្រធានCPWP និងនាយិកា GADC | 012 62 78 57 |
| -លោក សួន ប៊ុនស័ក្តិ | ប្រធានលេខាធិការដ្ឋាន CHRAC | 092 34 43 57 |
| -លោក ម៉ម សម្បត្តិ | នាយកប្រតិបត្តិ DPA | 012 77 97 34 |
| -លោក យ៉េង វីរៈ | នាយកប្រតិបត្តិអង្គការ CLEC | 012 80 12 35 |
| -លោក យង់ គិមអេង | ប្រធាន PDP-Center | 016 82 82 11 |
| -លោក ហ៊ឹម យន់ | អ្នកសម្របសម្រួលអង្គការ CISA | 012 94 70 22 |